ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## និស្សិតមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបានជ័យលាភីលេខ១ សម្រាប់ការប្រកួតសវនាការប្រឌិតថ្នាក់ជាតិ ស្តីពីនីតិមនុស្សធម៌អន្តរជាតិ ឆ្នាំ២០២៣ រៀបចំដោយ អ.វ.ត.ក.

**ភ្នំពេញ ប្រទេសកម្ពុជា** - កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣ ក្រុមនិស្សិតច្បាប់មួយក្រុមចំនួន៣នាក់ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ទទួលបានជ័យលាភីលេខ១ សម្រាប់ការប្រកួតសវនាការប្រឌិតថ្នាក់ជាតិ ស្តីពីនីតិមនុស្សធម៌អន្តរជាតិ ឆ្នាំ២០២៣ ដែលរៀបចំដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) និងសហការរៀបចំជាមួយ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) និងសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ (AUPP)។

ក្រុមនិស្សិតច្បាប់ចំនួនបួនក្រុម មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ និងសាកលវិទ្យាល័យជាតិគ្រប់គ្រង បានចូលរួមការប្រកួតសវនាការប្រឌិតថ្នាក់ជាតិ ស្តីពីនីតិមនុស្សធម៌អន្តរជាតិ ឆ្នាំ២០២៣ ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ និងវគ្គផ្តាច់ព្រ័ត្រ ដែលបានធ្វើឡើងនៅក្នុងបន្ទប់សវនាការរបស់ អ.វ.ត.ក.។ អ្នកប្រកបវិជ្ជាជីវៈច្បាប់ចំនួនប្រាំពីររូប រួមទាំងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បានបំពេញមុខងារជាចៅក្រមវិនិច្ឆ័យក្នុងការប្រកួតប្រជែងនេះ។

ក្រុមទទួលបានចំណាត់ថ្នាក់លេខ១ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺកញ្ញា ជា ដាលីនណា កញ្ញា តាំង គឹមសួ និងកញ្ញា ហ៊ិន សុខធីម ដែលពួកគេនឹងបន្តទៅចូលរួមប្រកួតប្រជែងថ្នាក់តំបន់ នៃការប្រកួតសវនាការប្រឌិត ស្តីពីនីតិមនុស្សធម៌អន្តរជាតិ ក្នុងឆ្នាំ២០២៤ ដែលរៀបចំនៅទីក្រុងហុងកុង។

កញ្ញា ជា ដាលីនណា សមាជិកម្នាក់ក្នុងក្រុមដែលទទួលបានចំណាត់ថ្នាក់លេខ១ បាននិយាយថា៖ «ខ្ញុំពិតជាសប្បាយចិត្ត និងមានមោទនភាពចំពោះពួកយើង។ សូមអរគុណដល់សហប្រឹក្សា និងអ្នកស្រាវជ្រាវរបស់ខ្ញុំ ដែលបានរួមចំណែកដល់ជោគជ័យទាំងអស់»។

កញ្ញា ជា ដាលីនណា បាននិយាយបន្ថែមថា៖ «ចំពោះនិស្សិតច្បាប់ផ្សេងទៀត ពួកគេគួរតែព្យាយាមចូលរួមការប្រកួតសវនាការប្រឌិតថ្នាក់ជាតិស្តីពីនីតិមនុស្សធម៌អន្តរជាតិ ដូចពួកយើង ព្រោះនេះជាឱកាស ដើម្បីទទួលបានចំណេះដឹងបន្ថែមនិងយល់ដឹងពីរបៀបធ្វើការស្រាវជ្រាវជាច្រើនទៀត។ បន្ទាប់ពីពួកយើងចូលរួមការប្រកួតនេះ យើងបានទទួលចំណេះដឹងនិងបទពិសោធន៍ជាក់ស្តែង ព្រោះវាមិនងាយស្រួលទេក្នុងការទទួលបានចំណេះដឹង [ដោយ] គ្រាន់តែសិក្សានោះទេ។ ជាឧទាហរណ៍ ការរៀនពីសម្មតិកម្ម [ករណីសិក្សា] តាមរយៈការប្រកួតប្រជែងគឺពិតជាល្អខ្លាំងណាស់»។

អ.វ.ត.ក. សូមអបអរសាទរដល់ប្អូនៗនិស្សិតទាំងអស់ដែលបានចូលរួម និងបានខិតខំប្រឹងប្រែងលើកកម្ពស់គោលការណ៍សំខាន់ៗស្តីពីនីតិមនុស្សធម៌អន្តរជាតិ និងរង់ចាំបន្តគាំទ្រយ៉ាងសកម្មដល់គំនិតផ្តួចផ្តើមទាំងនេះ ក្នុងអំឡុងពេលបំពេញមុខងារសេសសល់។

###

**កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន៖**

- **សម្រាប់ព័ត៌មានបន្ថែម៖**
  - *អ.វ.ត.ក. ICRC និង AUPP បើកកិច្ចប្រជុំ សម្រាប់ការរៀបចំការប្រកួតសវនាការប្រឌិតថ្នាក់ជាតិ ស្តីពីនីតិមនុស្សធម៌អន្តរជាតិ ឆ្នាំ២០២៣៖* https://t.ly/CyXDN
  - *អ.វ.ត.ក. និង ICRC ចុះអនុស្សរណៈយោគយល់គ្នា សម្រាប់ការរៀបចំ ការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ៖* https://t.ly/mWxOw


**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោក **គុណ ចិន្តា**

មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ

លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧

អ៊ីម៉ែល៖ kun.chenda@eccc.gov.kh